


*ដំណើរកម្សាន្តជុំវិញពិភពលោកជាមួយ ស្តេចមេឃ! អ្នកជំនាញរៀបចំដំណើរកម្សាន្តដ៏ប៉ិនប្រសប់!*

# ម៉ាកាវ-សិនជិន-ជូហាយ-គ័ងចូវ-ស្ពានកញ្ចក់-ផ្ទះទឹកកក (6ថ្ងៃ5យប់)

## ចេញដំណើរថ្ងៃទី........................................................................................................

### ថ្ងៃទី០១៖ ទីក្រុងភ្នំពេញ -ទីក្រុងម៉ាកាវ-ជូហៃ ( អាហារពេលថ្ងៃ និងល្ងាច )



ជួបជុំគ្នានៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ ដើម្បីធ្វើដំណើរឆ្ពោះទៅកាន់ **ទីក្រុងម៉ាកាវ នៅម៉ោង ៨ ព្រឹក** ។ ពេលទៅដល់ទីក្រុង**ម៉ាកាវ** និងមានការទទួលស្វាគមន៍ពីសំណាក់មគ្គុទ្ទេសទេសចរណ៍ដ៏ចំណាន ហើយបន្តធ្វើដំណើរទៅកាន់ទីក្រុងជូហាយ រួចបន្តជូនទៅ ពិសារអាហារពេលល្ងាចរួចជូនទៅសម្រាកនៅសណ្ឋាគារនៃទីក្រុងជូហៃ។

### ថ្ងៃទី០២៖ ទីក្រុងជូហៃ-ទីក្រុងគ័ងចូវ (អាហារព្រឹក ថ្ងៃ និងល្ងាច)



ពិសាអាហារព្រឹករួច ជូនទៅ **ទស្សនាវិថីគូស្នេហ៍ និង ទស្សនា រូបសំណាក់បុត្រីរបស់ស្តេចភុជង្គនាគឈរកាន់ត្បូងនិងមហាស្របជូហាយដែលល្បីមានរាងដូចសំបកលៀស** ហើយបន្តទៅ **រាជវាំងយៀនមីង** ដែលដូចទៅនឹងរាជវាំងចិននៅទីក្រុងប៉េកាំង ហើយបន្តទៅហាងលក់សូត្រ។ ទទួលទានអាហារពេលថ្ងៃត្រង់ បន្ទាប់មកធ្វើដំណើរទៅកាន់ទីក្រុងគ័ងចូវ ទៅទស្សនា **សួនឧទ្យានយេសៀវ** និងរូបសំណាក់តំណាងឲ្យទីក្រុងគ័ងចូវ រួចធ្វើដំណើរជូនទៅពិសារអាហារពេលល្ងាច ហើយជូនទៅសម្រាកនៅសណ្ឋាគារ។

### ថ្ងៃទី០៣៖ ទីក្រុងគ័ងចូវ-ទីក្រុងសិនជិន (អាហារព្រឹក ថ្ងៃ និងល្ងាច)



ពិសាអាហារពេលព្រឹក រួចធ្វើដំណើរជូនទៅ **ទីលានហ័រឆឹងនិងអគារខេនធុន** (Canton Tower) រួចបន្តទៅ **ឧទ្យានស្អាតប្រកួតកីឡាអាស៊ី** ហើយបន្តទៅហាងលក់ថ្នាំចិនបុរាណ។ រួចបន្តទៅទីក្រុងសិនជិន ទៅកំសាន្តនៅ **សួនអូបេ** ដែលមានទេសភាពស្រស់ស្អាត ជាប់នៅមាត់ទន្លេមានខ្យល់អាកាសបរិសុទ្ធ ជូនទៅពិសារអាហារពេលល្ងាច រួចជូនទៅសម្រាកនៅសណ្ឋាគារ។

### ថ្ងៃទី០៤៖ ទីក្រុងសិនជិន (អាហារព្រឹក ថ្ងៃ និងល្ងាច)



ទទួលទានអាហារពេលព្រឹក ទៅទស្សនា **ផ្សារទំនើប WANDA PLAZA** ដែលលោកអ្នកអាចដើរទិញទំនិញ និងបានទទួលបទពិសោធន៍ជិះជណ្តើរយន្តយ៉ាងវែងអស្ចារ្យ និងមានហាងលក់ម្ហូបអាហារយ៉ាងច្រើនប្រភេទ។ ហើយបន្តជូនទៅ ថតរូបនៅ**អគារឃីងឃី១០០** ហើយបន្តជូនឡើង **អគារខ្ពស់ ៦៩ជាន់ ដែលលោកអ្នកអាចមើលឃើញទិដ្ឋភាពនៃទីក្រុងសិនជិនទាំងមូល និងទីក្រុងហុងកុងផងដែរ**។ ពិសារអាហារពេលល្ងាចរួច ជូនទៅសម្រាកនៅសណ្ឋាគារ។

### ថ្ងៃទី០៥៖ ទីក្រុងសិនជិន-ទីក្រុងជូហាយ (អាហារព្រឹក ថ្ងៃ និងល្ងាច)



ពិសារអាហារពេលព្រឹករួច ធ្វើដំណើរទៅកាន់ទីក្រុងតុងគ័ង ដើម្បីទៅលេងកំសាន្ត**ស្ពានកញ្ចក់ និងចូលលេងកំសាន្តផ្ទះទឹកកក**។ ពិសារអាហារពេលថ្ងៃត្រង់រួច ជូនទៅហាង**លក់ត្បូងមថ្ម និង គុជខ្យង**និងហាង**លក់ផលិតផលធ្វើពីឬស្សី**។ ពិសារអាហារពេលល្ងាចទៅសម្រាកសណ្ឋាគារ។

## ថ្ងៃទី០៦៖ ទីក្រុងជូហាយ-ទីក្រុងម៉ាកាវ (អាហារព្រឹក និង ថ្ងៃ)

ទទួលទានអាហារពេលព្រឹក រួចជូនទៅទស្សនា ស្ពានឆ្លងមហាសមុទ្រ3ប្រទេសហុងកុង-ជូហៃ-ម៉ាកាវ **ដែលវែងដាច់កន្ទុយភ្នែក** ។ បន្ទាប់មកធ្វើដំណើរទៅកាន់ម៉ាកាវ ទៅ ថតរូបកំសាន្តនៅកំពង់ផែនេសាទ ដែលជាសួនកំសាន្តដំបូងគេបង្អស់នៅទីក្រុងម៉ាកាវ មានសំណង់ដូចទៅនឹងប្រទេសអ៊ីតាលី រួច ជូនទស្សនាព្រះវិហារកាតូលិកស្រ្មីតផូល (Ruin of St. Paul) ហាងលក់ទំនិញប្រចាំតំបន់ បន្តទៅ ថតរូបទូអែសហ្វៃលម៉ាកាវ (Macau Eiffet Tower) ទស្សនាការសំដែង Show ត្បូងពេជ្រដ៏ធំនៅកាស៊ីណូដ៏ល្បី ។ ទស្សនា កាស៊ីណូវិនិធាន ដើរកំសាន្តដោយសេរីនៅក្នុងនោះ រួចបន្តជូនទៅប្រលានយន្តហោះម៉ាកាវដើម្បីធ្វើការហោះហើរមកកាន់ទីក្រុងភ្នំពេញវិញ។











### ពត៏មានបន្ថែមសំរាប់ដំណើរកំសាន្ត

- សំរាប់ការចុះឈ្មោះតម្រូវអោយអតិថិជនមានលិខិតឆ្លងដែនដែលមានសពុលភាពចាប់ពី៦ខែឡើងទៅ នឹងមិនមានការរហែក
- ឬ ស្នាមប្រលាក់ ហើយតម្រូវអោយសល់២សន្លឹកគិតចាប់ពីថ្ងៃចេញដំណើរកំសាន្ត។
- ករណីអតិថិជនចុះឈ្មោះដំណើរកំសាន្តតែម្នាក់ឯង ក្រុមហ៊ុននឹងរៀបចំអោយស្នាក់នៅជាមួយភ្ញៀវដ៏ទៃ ឬអ្នកដឹកនាំក្រុម ( ១ បន្ទប់ស្នាក់នៅ ២-៣ នាក់)។ ក្នុងករណីមិនមានភ្ញៀវសេស ក្រុមហ៊ុនតម្រូវអោយអតិថិជនបង់ប្រាក់បន្ថែមសំរាប់បន្ទប់ស្នាក់នៅម្នាក់ឯង។
- សម្រាប់កូនក្មេងក្រោមអាយុ១១ឆ្នាំត្រូវគេងគ្រែជាមួយឪពុកម្តាយ ប្រសិនបើចង់អោយមានគ្រែតម្រូវអោយបង់តំម្លៃដូចជាមនុស្សធំ។
- តម្លៃខាងលើរួមបញ្ចូលពន្ធព្រលានយន្តហោះ(អតិថិជនមិនមានសិទ្ធិដកដោយខ្លួនឯងទេ)។
- ក្រុមហ៊ុនមិនទទួលខុសត្រូវលើគ្រោះធម្មជាតិ សង្គ្រាម ឧប្បទ្ទវហេតុដែលបានកើតឡើងពេលធ្វើដំណើរ ឬបង្កឡើងដោយអគ្គីភ័យ ដោយជំងឺផ្ទាល់ខ្លួន ជំងឺឆ្លង ការពុលអាហារ នឹងចោរកម្ម ឬហេតុការដែលបង្កឡើងដោយសកម្មភាពអតិថិជនចិត្តឯង។
- ក្រុមហ៊ុនមិនទទួលខុសត្រូចំពោះការលុបចោល ឬពន្យាជើងហោះហើររបស់ក្រុមហ៊ុនអាកាសចរនោះទេ។

### កំណត់សម្គាល់៖

- ក្នុងករណីរកឃើញភ្ញៀវមានវិជ្ជមានជំងឺកូវីដ ឬជំងឺឆ្លងផ្សេងៗនោះជាទំនួលខុសត្រូវរបស់ភ្ញៀវ
- ក្រុមហ៊ុនសូមរក្សាសិទ្ធិក្នុងការកែប្រែតម្លៃ និងកម្មវិធីដំណើរកំសាន្ត ក្នុងករណីចាំបាច់ ដោយពុំបានជម្រាបជូនដំណឹងទុកជាមុន


ទំនាក់ទំនងផ្នែកលក់
099 777 183 / 099 555 713
069 517 888 / 012 517 888
Sky King Tours
info@skykingtour.com
Sky King Tours
@skykingtour
Sky King Tours
www.skykingtour.com
ផ្ទះលេខ 401 ផ្លូវ128 ( ផ្លូវកម្ពុជាក្រោម កែងស្តុបដេអិន ) សង្កាត់មិត្តភាព ខណ្ឌ7មករា រាជធានីភ្នំពេញ
023 23 87 67